**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN : ....648....
Date: 13.03.14 Time: 4.00
For : ....GMAC....

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៣៧/១៤ ក.ប/ប.ក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០១៤

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមអធិការកិច្ចការងារតែមួយ

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- តាមការចាំបាច់របស់ក្រសួង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមអធិការកិច្ចការងារតែមួយ ក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យចុះទៅបំពេញការងារតាមតួនាទី និងភារកិច្ចនៅតាមសហគ្រាស គ្រឹះស្ថានទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ។

**ប្រការ២.-**

សមាសភាពក្រុមអធិការកិច្ចការងារតែមួយ រួមមាន៖

| | | |
|---|---|---|
| ១-មន្ត្រីរាជការ | នៃនាយកដ្ឋានអធិការកិច្ចការងារ | ចំនួន ០១ នាក់ |
| ២-មន្ត្រីរាជការ | នៃនាយកដ្ឋានពេទ្យការងារ | ចំនួន ០១ នាក់ |
| ៣-មន្ត្រីរាជការ | នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | ចំនួន ០១ នាក់ |
| ៤-មន្ត្រីរាជការ | នៃនាយកដ្ឋានវិវាទការងារ | ចំនួន ០១ នាក់ |
| ៥-មន្ត្រីរាជការ | នៃនាយកដ្ឋានការងារកុមារ | ចំនួន ០១ នាក់ |
| ៦-មន្ត្រីរាជការ | នៃបេឡាជាតិរបបសន្តិសុខសង្គម | ចំនួន ០១ នាក់ |
| ៧-មន្ត្រីរាជការ | នៃនាយកដ្ឋានព័ត៌មានទីផ្សារការងារ | ចំនួន ០១ នាក់ |
| ៨-មន្ត្រីរាជការ | នៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា | ចំនួន ០១ នាក់។ |

**ប្រការ៣.-**

ក្រុមអធិការកិច្ចការងារតែមួយ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ត្រួតពិនិត្យការអនុវត្តច្បាប់ បទប្បញ្ញត្តិច្បាប់ និងបទបញ្ជាពាក់ព័ន្ធជាមួយច្បាប់ស្តីពីការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាដែលទាក់ទងនឹងលក្ខខណ្ឌទូទៅនៃការងារ និងសន្តិសុខការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិច្បាប់ និងបទបញ្ជា ដែលទាក់ទងនឹងលក្ខខណ្ឌជីវភាពនៃកម្មករនិយោជិត
- ត្រួតពិនិត្យបទបញ្ជាដែលទាក់ទងនឹងលក្ខខណ្ឌការងារ និងការការពារកម្មករនិយោជិតក្នុងពេលប្រកបវិជ្ជាជីវៈរបស់ខ្លួន
- ត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់នូវការអនុវត្តច្បាប់ស្តីពីការងារ បទបញ្ជាស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានាស្តីពីការងារ ដើម្បីធានាឱ្យបានពិតប្រាកដនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់សម្រាប់កម្មករនិយោជិត និងនិយោជក
- ត្រួតពិនិត្យការអនុវត្តបែបបទស្តីពីសហគ្រាស គ្រឹះស្ថាន
- ធ្វើអធិការកិច្ចការងារហត្ថពលកម្មបរទេស និងកម្មករនិយោជិតខ្មែរ (បណ្ណីងស្តីពីបុគ្គលិក បណ្ណីងចលនាបុគ្គលិក និងការស្នើសុំកូតា)
- ត្រួតពិនិត្យបញ្ជីបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងចំនួនកម្មករនិយោជិត
- ត្រួតពិនិត្យលើការអនុវត្តច្បាប់ស្តីពីការងារ ពិសេសរាល់ប្រកាសដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារនៅកន្លែងធ្វើការ
- ត្រួតពិនិត្យ វិភាគ និងកែលម្អលើលក្ខខណ្ឌ អនាម័យ សុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតនៅកន្លែងធ្វើការ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ការងារ ជម្ងឺឆ្លង ការដួលសន្លប់និងជម្ងឺវិជ្ជាជីវៈ

- ត្រួតពិនិត្យ បទបញ្ញាការងារពាក់ព័ន្ធទៅនឹងលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារក្នុងការ ការពារទប់ស្កាត់ហានិភ័យវិជ្ជាជីវៈនៅកន្លែងធ្វើការ
- ត្រួតពិនិត្យលើការកសាងបណ្តាញគ្រូពេទ្យសហគ្រាសព្រមទាំងលក្ខខណ្ឌ និងបេសកកម្ម សេវាពេទ្យសហគ្រាស
- ត្រួតពិនិត្យលើការជម្រុញ ការពិនិត្យកាយសម្បទាដល់កម្មករនិយោជិត និងអំពីសុខភាព កម្មករនិយោជិតដែលប៉ះពាល់ ឬខូចខាតដោយសារប្រកបការងារ
- ជំរុញការបង្កើតក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ និងគណៈកម្មការសុវត្ថិភាព នៅកន្លែងធ្វើការ
- ជំរុញការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិតប្រតិភូបុគ្គលិក និងសហជីព។
- ត្រួតពិនិត្យហត្ថពលកម្មបរទេស ដែលមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ត្រួតពិនិត្យសៀវភៅការងារ និងប័ណ្ណការងារហត្ថពលកម្មបរទេស
- ត្រួតពិនិត្យសៀវភៅការងារ និងប័ណ្ណការងារកម្មករនិយោជិតខ្មែរ
- ត្រួតពិនិត្យការចេញប័ណ្ណការងារ សៀវភៅការងារ និងការផ្តល់ទិដ្ឋាការការងារដល់កម្មករ និយោជិតខ្មែរ និងហត្ថពលកម្មបរទេស
- ត្រួតពិនិត្យការអនុវត្តរបស់អង្គការវិជ្ជាជីវៈ
- ត្រួតពិនិត្យការអនុវត្តរបស់ប្រតិភូបុគ្គលិក
- ត្រួតពិនិត្យការចុះបញ្ជិការបស់អង្គការវិជ្ជាជីវៈ ប្រតិភូបុគ្គលិក អនុសញ្ញារួម និងភាពជា តំណាងរបស់អង្គការវិជ្ជាជីវៈ
- ជួបជាមួយកម្មករនិយោជិត ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព
- ផ្សះផ្សាវិវាទការងារ ឬបណ្តឹងនៃប.ស.ស
- ត្រួតពិនិត្យអធិការកិច្ចការងារពលកម្មកុមារ
- ត្រួតពិនិត្យការអនុវត្តកម្មករនិយោជិត ដែលមានអាយុក្រោម១៨ឆ្នាំ
- ត្រួតពិនិត្យការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងទម្រង់ផ្សេងៗទៀតនៃ ពលកម្មកុមារ
- ត្រួតពិនិត្យលក្ខខណ្ឌ នៃមុខរបរសម្រាប់អនីតិជន (អាយុ ១៥ឆ្នាំទៅក្រោម ១៨ឆ្នាំសម្រាប់ ការងារស្ត្រី និងកុមារ)
- ធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅ ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាជាធរមាននានា ដែលមានការទាក់ទង នឹងវិស័យរបបសន្តិសុខសង្គម
- ជូនដំណឹង និងផ្តល់ដំបូន្មានបច្ចេកទេសចំពោះនិយោជក និងកម្មករនិយោជិត ដែលជា សមាជិកនៃ ប.ស.ស អំពីមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការគោរពច្បាប់ និងបទបញ្ញា ដទៃទៀតនៃរបបសន្តិសុខសង្គម
- ផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច នូវការមិនគប្បី ឬការរំលោភផ្សេងៗទាក់ទងនឹង វិធានការអនាម័យ និងសន្តិសុខកម្មករនិយោជិត
- ត្រួតពិនិត្យ និងណែនាំសហគ្រាស គ្រឹះស្ថានឲ្យចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខ សង្គម
- ត្រួតពិនិត្យបញ្ជីបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងចំនួនកម្មករនិយោជិត
- ត្រួតពិនិត្យការបង់ភាគទានប្រចាំខែរបស់សមាជិក ប.ស.ស

- ត្រួតពិនិត្យករណីសហគ្រាសពុំទាន់បានបង់ប្រាក់ពិន័យលើការបង់ភាគទានផ្នែកហានិភ័យការងារ ឬផ្នែកផ្សេងៗដែលមានចែងក្នុងច្បាប់
- ត្រួតពិនិត្យលើសហគ្រាស ឬកម្មករនិយោជិតបានបន្លំឯកសារចង់បានតាវលិកពី ប.ស.ស
- ត្រួតពិនិត្យលើសហគ្រាសផ្តល់ទិន្នន័យរបស់កម្មករនិយោជិតមិនបានត្រឹមត្រូវ
- អង្កេតគ្រោះថ្នាក់ការងារ ឬជំងឺវិជ្ជាជីវៈ
- ស៊ើបអង្កេតអំពីស្ថានភាពអ្នកនៅក្នុងបន្ទុក ឬកំណត់ឲ្យបានច្បាស់អំពីស្ថានភាពសិទ្ធិវន្ត
- ត្រួតពិនិត្យករណីនិយោជកដកយកភាគទានពីកម្មករនិយោជិតមិនត្រឹមត្រូវ ដើម្បីដាក់មកក្នុងរបបសោធនដោយការកាត់បន្ថយប្រាក់ឈ្នួល
- ត្រួតពិនិត្យកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង
- សិក្សាស្រាវជ្រាវ ស្រង់ទិន្នន័យ អប់រំ ដោះស្រាយ និងផ្សព្វផ្សាយគោលការណ៍ និងសេចក្តីសម្រេចផ្សេងៗរបស់រាជរដ្ឋាភិបាល និងក្រសួង។

**ប្រការ៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត "ដើម្បីជូនជ្រាប និងសហការ"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត "ដើម្បីជូនជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ